ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកោះកុង

សាលាដំបូងខេត្តកោះកុង

សំណុំរឿងព្រហ្មទណ្ឌលេខ៧៥
ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧

សាលក្រម
លេខ ១៣ "ឃ"
ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក[redacted]ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

**ដើម្បីជំនុំជម្រះ**

សំណុំរឿងព្រហ្មទណ្ឌលេខ:៧៥ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧ ដែលរួមមានជនជាប់ចោទ៖

១.ឈ្មោះ [redacted]ស៊ី ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរឥស្លាម ខ្មែរ ទីកន្លែងកំណើតនៅភូមិត្រើយកោះ ឃុំត្រើយកោះ ស្រុកកំពត ខេត្តកំពត ទីលំនៅបច្ចុប្បន្ននៅភូមិ០៤ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ឪពុក ឈ្មោ[redacted] (រ) ម្តាយឈ្មោះ [redacted]) ទោសពីមុនគ្មាន ។ (គេចខ្លួន)

ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង កាលពីថ្ងៃទី១០, ១៣ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២.ឈ្មោ[redacted] ច័ន្ទនួន ភេទស្រី អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិជើងក្តី ឃុំធម៌តាអរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទីលំនៅបច្ចុប្បន្ននៅភូមិអណ្តូងទឹកស្រុកបូទុមសាគរ ខេត្តកោះកុង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្តីឈ្មោះ [redacted]ាសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ: សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង កាលពីថ្ងៃ ទី១០, ១៣ ខែមីនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៩,៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣.ឈ្មោ[redacted]បក្និណា ភេទស្រី អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើតនៅភូមិ

Scanned by CamScanner

ត្រើយកោះ ឃុំត្រើយកោះ ស្រុកកំពត ខេត្តកំពត ទីលំនៅបច្ចុប្បន្ននៅភូមិ៤ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ឪពុកឈ្មោះ[redacted](ស) ម្ដាយឈ្មោះ[redacted]) ប្ដីឈ្មោះ [redacted] ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិអណ្ដូងទឹក ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង កាលពីថ្ងៃ ទី១០, ១៣ ខែមីនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ២៩,៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

លោកមេធាវី[redacted]ហួន ជាមេធាវី ការពារសិទ្ធិឲ្យជនជាប់ចោទ ។

លោកមេធាវី [redacted]សុវណ្ណា ជាមេធាវីតំណាងឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាក់សាក់ ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជម្រះ លេខ២០៦៩ ត.ព ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកោះកុង។

- បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ១៣៧ អ.យ/១៧ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកោះកុង ។

- បានឃើញដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ ១៣៩ ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១៧ របស់ប្រធានសាលាដំបូងខេត្តកោះកុង។

## អង្គហេតុមានដូចនៅ

កាលពីថ្ងៃទី១០.០៣.២០១៧ ស្ថិតក្នុងស្នាក់ការគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រសាក់ ក្នុងភូមិអណ្ដូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង ឈ្មោះ[redacted]អ៊ី សើ ដែលជានាយកដ្ឋានសាខាអណ្ដូងទឹក,ឈ្មោះ [redacted] ច័ន្ទនួន ជាប្រធានបេឡា និងឈ្មោះ[redacted] លក្ខិណា ជាមន្ត្រីផ្នែកបេឡា បានធ្វើការបូកសរុបបញ្ជី និងបានយកលុយចំនួន៨៣.២២៨ ដុល្លារអាមេរិក និងលុយខ្មែរចំនួន៣១៣.៩៩៥.១០០៛ ក្រោយពីបូកសរុបបញ្ជីរួចដាក់ចូលក្នុងទូរដែករបស់គ្រឹះស្ថានមីក្រូហិរញវត្ថុប្រាសាក់ ព្រោះអ្នកទាំងបីមានសិទ្ធិក្នុងការកាន់កូនសោបន្ទប់ដាក់ទូរដែក និងកូនសោរដែក ម្នាក់មួយរៀងៗខ្លួន។ លុះនៅថ្ងៃទី១២.០៣.២០១៧ ឈ្មោះ[redacted]ណារិទ្ធ ដែលជាសន្តិសុខយាម បានឃើញឈ្មោះ [redacted] អ៊ីសើ ដែលជានាយកដ្ឋានសាខាបានចូលទៅក្នុងទីស្នាក់ការ មានពាក់អាវធំពណ៌ខ្មៅ ហើយបានឡើងទៅជាន់ទី២ ដែលជាបន្ទប់ធ្វើការរបស់គាត់ ហើយក៏បានចុះមកអង្គុយលេងជាមួយខ្លួនបានប្រហែល៥នាទីភ្លើងក៏ដាច់ ឈញមោះ [redacted] អ៊ីសើ បានឡើងទៅលើ និងបានដើរចេញមកវិញដោយក្នុងស្ថានភាពខ្លួនប្រាណបែកញើសជោក និងមានពាក់អាវធំពណ៌ខ្មៅជាប់ខ្លួនរហូត ហើយក៏បានទាញម៉ូតូជិះចេញទៅក្រៅដោយមានស្ពាយកាបូបមួយទៅផង។ លុះនៅថ្ងៃទី១៣.០៣.២០១៧ ឈ្មោះ[redacted] អ៊ីសើ ដែលជានាយកសាខាមិនឃើញមកធ្វើការ ហើយទូរដែករបស់គ្រឹះស្ថានមីក្រូហិរញវត្ថុប្រាសាក់បើកមិនបានដោយសារឈ្មោ[redacted]អ៊ីសើ ពុំបានផ្ដល់លេខកូដទូរដែកទៅឲ្យគេ ដូចនេះថ្នាក់លើរបស់ប្រាសាក់ក៏បានបង្កើតគណៈការត្រួតពិនិត្យទូរដែកទើបដឹងថានាយកសាខាឈ្មោះ [redacted] អ៊ីសើ បានលួចយកប្រាក់របស់សាខាអស់ចំនួន៥៥លានរៀល និងប្រាក់ដុល្លារចំនួន៨១៩៧០ ដុល្លារអាមេរិក។

-តុលាការប្រកាសបើកសវនាការ

Scanned by CamScanner

-តុលាការប្រកាសអំពីសមាសភាពជំនុំជម្រះ

-តុលាការសួរអំពីអត្តសញ្ញាណជនជាប់ចោទ

-តុលាការប្រាប់សិទ្ធិដល់ជនជាប់ចោទ

-តុលាការប្រាប់សិទ្ធិដល់សាក្សី

-ជនជាប់ចោទមិនជំទាស់ និងសមាសភាពជំនុំជម្រះទេ

**<u>នាពេលសវនាការ</u>**

-តាមចម្លើយរបស់ជនសង្ស័យឈ្មោះ [redacted]លក្ខិណា បានឆ្លើយសារភាពថា: ខ្លួនបានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់សាខាអណ្តូងទឹកផ្នែកបេឡាធិការ តាំងពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ អក់ម្លេះ ដោយខ្លួនមិនបានកាន់សោទូរនោះទេ។ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ឈ្មោះ [redacted] អ៊ីសើ នាយកសាខាអណ្តូងទឹកបានប្រគល់សោមកឲ្យខ្លួនកាន់ រួមមាន: សោបន្ទប់ទីមួយ សោបន្ទប់ទីពីរ សោទូរដែកខាងក្នុងមួយ និងសោទូរដែកបន្ទប់បម្រុងមួយ សរុបទាំងអស់មានចំនួនបួនសោ ហើយមិនដែលមានបញ្ហាអ្វីនោះទេ។ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំពីរ និងសាមសិបនាទីព្រឹក ខ្លួនបានទៅចាក់សោទូបន្ទប់ធម្មតា ហើយបានទៅចាក់សោទូដែកដោយមានគ្នាចំនួនបីនាក់ រួមមានឈ្មោះ [redacted]អ៊ីសើ ឈ្មោះ [redacted]ច័ន្ទនួន និងខ្លួន ដើម្បីយកប្រាក់បើក និងដកប្រាក់ឲ្យអតិថិជន។ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំពីរ និងដប់នាទីព្រឹក ខ្លួនបានមកធ្វើការធម្មតា ហើយឈ្មោះ[redacted] ច័ន្ទនួន ដែលជាប្រធានបេឡា បានហៅខ្លួនឲ្យចាក់សោដូចរាល់ដង និងមានឈ្មោះ[redacted]ផល្លី ប្រធានស្តីទីសាខា បានចាក់សោបន្ទប់ទីមួយ ទីពីរ និងចាក់សោបន្ទប់ទីពីរ ហើយបន្ទប់ទីបី ព្រមទាំងបានចាក់សោរទូរដែក ដោយឈ្មោះ [redacted]ផល្លី បានបង្វិលលេខកូដសម្ងាត់គឺលេខចាស់ ប៉ុន្តែឈ្មោះ [redacted] ផល្លី បានបង្វិលលេខកូដ ទូរដែកមិនចេញជាច្រើនលើកទើបមកឈ្មោះ [redacted] ច័ន្ទនួន ដែលជាប្រធានបេឡា បានទាក់ទងថ្នាក់លើដែលជាប្រធានគ្រប់គ្រងតំបន់ និងអ្នកជំនាញទូដែក បានមកបើកទូរដែក តែបើកមិនចេញ ហើយក៍ទម្លុះទូដែកនោះតែម្តង។ ចំណែកខ្លួនបានចេញមកខាងក្រៅដើម្បីទទួលអតិថិជន។ នៅពេលដែលទម្លុះទូដែក និងបានរាប់ប្រាក់រួចរាល់ហើយ ប្រធានបេឡា និងប្រធានស្តីទី បានចេញមកខាងក្រៅ ហើយខ្លួនបានសួរថា "យ៉ាងម៉េចហើយ" តែប្រធានបេឡា និងប្រធានស្តីទីបានគ្រវីក្បាល ហើយខ្លួនបានទៅបម្រើការងារធម្មតា និងបានបិទបញ្ជី ។ បន្ទាប់មកប្រធានតំបន់ បានហៅបុគ្គលិកមកប្រជុំមួយភ្លែត តែមិនបានប្រជុំទេដោយសារម៉ោងប្រាំពីរយប់ហើយ។ លុះព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ វេលា ម៉ោងប្រាំពីរ និងសែសិបនាទីព្រឹក ប្រធានតំបន់បានហៅបុគ្គលិកប្រជុំម្នាក់ម្តងៗដោយបានប្រាប់ថា "សាខាយើងមានបាត់ប្រាក់" ហើយប្រធានសាខាបានឲ្យពួកខ្លួនមកធ្វើការធម្មតាវិញ។

-តាមចម្លើយរបស់ជនសង្ស័យឈ្មោះ[redacted]ច័ន្ទនួន បានឆ្លើយសារភាពថា: ខ្លួន បានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់បានអស់រយៈពេលពីរឆ្នាំ និងប្រាំមួយខែមកហើយ។ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦ ខ្លួនបានកាន់សោតាំងពីនៅឋានៈជាបុគ្គលិកមកម្លេះ ដែលសោរទាំងនោះរួមមាន: សោបន្ទប់ប្រតិបត្តិការ សោបន្ទប់ត្រៀមបម្រុង សោទូបម្រុង (ទូដែកនៅខាងក្នុងសម្រាប់ដាក់ប្រាក់) និងសោទូដែកសម្រាប់ដាក់ប្រាក់ គឺទូដែកខ្នាតតូច ហើយអ្នកដែលកាន់សោរនេះមានគ្នាបីនាក់រួមមាន: ឈ្មោ[redacted] អ៊ីសើ កាន់សោបន្ទប់បម្រុង បន្ទប់ប្រតិបត្តិការ និងលេខកូដទូបម្រុង។ ខ្លួន ជាប្រធានបេឡា កាន់សោបន្ទប់ប្រតិបត្តិការ បន្ទប់ត្រៀមបម្រុង សោទូបម្រុង និងលេខកូដទូប្រតិបត្តិការ។ ចំណែកឈ្មោះ [redacted]លក្ខិណា ឋានៈជាបេឡា កាន់សោរបន្ទប់ប្រតិ

Scanned by CamScanner

ក្តីការ សោបន្ទប់ត្រៀមប្រុង សោទូត្រៀមប្រុង និងសោទូប្រតិបត្តិការ។ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំមួយ និងសាមសិបនាទីព្រឹក ជារៀងរាល់ថ្ងៃ ខ្លួនទៅបម្រើការងារនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ហើយតែងតែរង់ចាំអ្នកកាន់សោពីរនាក់ទៀត ទើបអាចចាក់សោរបាន។ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំមួយ និងសាមសិបនាទី ខ្លួនបានមកធ្វើការមុនគេ ចំណែកនាយកសាខាឈ្មោ[redacted]អ៊ីសេ អវត្តមានដោយត្រូវទៅរៀននៅភ្នំពេញ ដោយប្រាប់មន្ត្រីឥណទានថា បានផ្ទេរទៅឲ្យឈ្មោះ [redacted]ផល្លី ប្រធានស្តីទីសាខា ប៉ុន្តែនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧ ឈ្មោះ [redacted] អ៊ីសេ មិនបានទៅរៀននៅភ្នំពេញទេ ហើយនាយកភូមិភាគ និងនាយកសាខាខេត្តកោះកុង បានទូរស័ព្ទខ្លួនសួររកនាយកសាខាឈ្មោះ [redacted] អ៊ីសេ ទៅណា? ហើយខ្លួនបានប្រាប់វិញថា "ឈ្មោះ [redacted] អ៊ីសេ បានឡើងទៅប្រជុំនៅភ្នំពេញ" ប៉ុន្តែនាយកសាខាភូមិភាគ និងនាយកសាខាខេត្តកោះកុង បានប្រាប់វិញថា មិនឃើញទេ។ បន្ទាប់មកខ្លួនក៏បានទំនាក់ទំនងជាមួយសន្តិសុខឈ្មោះ [redacted]ប៊ុនធឿន ហើយសន្តិសុខនោះបានប្រាប់វិញថា "នៅទេ គាត់ចេញបាត់តាំងពីម៉ោងប្រហែលប្រាំបួនជាង កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧"។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំមួយល្ងាច ខ្លួនបានចេញពីខេត្តកោះកុងទៅអណ្តូងទឹកវិញប្រហែលម៉ោងប្រាំពីរនិងសូន្យនាទីយប់ ខ្លួនបានសួរសន្តិសុខ ហើយសន្តិសុខបានបង្ហាញប្រអប់បាយដែលសន្តិសុខបានទិញបាយឲ្យ ហើយខ្លួនក៏បានទូរស័ព្ទមកនាយកសាខាខេត្ត កោះកុង ហើយនាយកសាខាខេត្តកោះកុង បានប្រាប់ថាមិនឃើញទេ។

-ដើមបណ្តឹង ឈ្មោ[redacted]ណារិទ្ធ បានឆ្លើយបំភ្លឺថា: ឈ្មោះ[redacted]អ៊ីសេ បានចូលបម្រើការងារជានាយកសាខាអណ្តូងទឹកកាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥ បានធ្វើសកម្មភាពលួចយកប្រាក់ក្នុងទូដែករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់នៅសាខាអណ្តូងទឹកអស់ប្រាក់ចំនួន ៥៥ លានរៀល និង៨១,៩៧០ ដុល្លារអាមេរិក។ ឈ្មោះ[redacted] អ៊ីសេ មិនបានចូលមកធ្វើការនៅថ្ងៃទី១៣ខែមីនាឆ្នាំ២០១៧ ហើយតំណាងស្ថាប័នមីក្រូហិរញ្ញវត្ថុប្រាសាក់បានធ្វើការទំនាក់ទំនងតាមទូរស័ព្ទតែទាក់ទងពុំបាន ។ និងបានសួរនាំបុគ្គលិកសន្តិសុខដែលប្រចាំការនៅអណ្តូងទឹក បាននិយាយថា: កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ប្រហែលប្រាំបួនព្រឹកឈ្មោះ[redacted] អ៊ីសេ បានចូលទៅបន្ទប់ធ្វើការងាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានប្រហែលមួយនាទី ភ្លើងបានដាច់ និងប្រព័ន្ធកាម៉េរ៉ាសុវត្ថិភាពត្រូវបានកាត់ផ្តាច់ទាំងស្រុង។ ដោយឈ្មោះ [redacted] ណារិទ្ធ បាននិយាយថា: នៅវេលាម៉ោងប្រមាណប្រាំបួន និងសាមសិបនាទីព្រឹក ឈ្មោះ[redacted] អ៊ីសេ បានចាកចេញពីសាខារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ដោយស្ពាយកាបូបពណ៌ ខ្មៅ ដែលមានសម្ភារៈពេញ។ បន្ទាប់មកថ្នាក់គ្រប់គ្រងបានបញ្ជូនបុគ្គលិកមកសាខា ដោយបង្កើតគណៈកម្មការ ត្រួតពិនិត្យទូដែក ក្រោយពីបានពិនិត្យ និងផ្ទៀងផ្ទាត់សាច់ប្រាក់រួច គណៈកម្មការត្រួតពិនិត្យបានបញ្ជាក់ថា: ឈ្មោះ[redacted]អ៊ីសេ ពិតជាបានលួចយកប្រាក់ពីទូរដែកអស់ចំនួន៥៥ លានរៀល និងប្រាក់ដុល្លារអាមេរិកចំនួន៨១៩៧០ ដុល្លារអាមេរិកប្រាកដមែន។

-សាក្សីឈ្មោះ[redacted] ណារិទ្ធ បានអវត្តមាន។ ក្រឡាបញ្ជីបានអានអំណានកំណត់ហេតុនៅតំណាក់ កាលចៅក្រមស៊ើបសួរ បានឆ្លើយបំភ្លឺថា: កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំបី និងសូន្យនាទីព្រឹក ខ្លួនជាសន្តិសុខរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់ប្រាសាក់សាខាអណ្តូងទឹក។ នៅពេលដែលខ្លួនកំពុងយាមនៅជាន់ខាងក្រោម ខ្លួនឃើញឈ្មោ[redacted]អ៊ីសេ ជានាយកសាខាបានដើរចូលក្នុងស្នាក់ការ ហើយបានឡើងទៅជាន់ទីពីរ ដែលជាបន្ទប់ធ្វើការរបស់ឈ្មោះ [redacted] អ៊ីសេ។ ឈ្មោះ [redacted]អ៊ីសេ បានចុះមកជាន់ខាងក្រោមដែលជាកន្លែងខ្លួនយាម និងបានបើកទូរទស្សន៍មើលបានប្រហែលប្រាំនាទីភ្លើងក៏ដាច់ ហើយ ឈ្មោះ [redacted] អ៊ីសេ

បានឡើងទៅលើវិញ និងខ្លួនបានឃើញឈ្មោះ [redacted] អ៊ីសេី ដើរចេញពីបន្ទប់ទឹកដោយមានសភាព សើមជោគនិងបានទៅអង្គុយលេងនៅកន្លែងចំណតម៉ូតូខាងមុខសាខា។បន្ទាប់មកឈ្មោះ [redacted] អ៊ីសេី បានប្រើឈ្មោះ [redacted] ប៊ុនធឿន ដែលជាសន្តិសុខ ទៅទិញបាយឲ្យនៅពេលដែលហូបបាយរួចឈ្មោះ [redacted] អ៊ីសេី បានជិះម៉ូតូចេញទៅដោយមានកាបូបស្ពាយមួយ ប៉ុន្តែមិនបានយកចូលក្នុងស្នាក់ការទេ ហើយខ្លួនបានសួរឈ្មោះ [redacted] អ៊ីសេី ថា "នាយកទៅណា ហើយឈ្មោះ [redacted] អ៊ីសេី បានឆ្លើយថា ទៅប្រជុំនៅភ្នំពេញ"។

តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ណារិទ្ធ ជាលើកទីពីរបានឆ្លើយបំភ្លឺថា: កាលពីថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំពីរព្រឹក ខ្លួនបានទៅយាមនៅសាខា។ ខ្លួនបានឃើញឈ្មោះ [redacted] អ៊ីសេី ដែលជានាយកសាខាអណ្ដូងទឹក ទៅធ្វើការនៅសាខា ខ្លួនបានឃើញឈ្មោះ [redacted] អ៊ីសេី រៀបចំចេញដំណើរ ;ហើយខ្លួនបានសួរថា "នាយកសាលាទៅណា ហើយឈ្មោះ [redacted] អ៊ីសេី បានឆ្លើយថា ទៅហូបការគេ នៅត្រពាំងរូង"។ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំបួន និងសូន្យនាទីព្រឹក ខ្លួនបានឃើញឈ្មោះ [redacted] អ៊ីសេី មកការិយាល័យប្រាសាក់សាខាអណ្ដូងទឹក ហើយបានអង្គុយមើលទូរទស្សន៍។ បន្ទាប់មកបានឡើងទៅសម្រាកនៅបន្ទប់ធ្វើការនៅជាន់ទីពីរ។ រហូតដល់ម៉ោងដប់បី និងសូន្យនាទី ឈ្មោះ [redacted] អ៊ីសេី បានជិះម៉ូតូចេញទៅក្រៅបាត់តែម្ដង។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំបីព្រឹក ខ្លួនបានឃើញឈ្មោះ [redacted] អ៊ីសេី ចូលមកសាខាអណ្ដូងទឹក និងបានឡើងទៅបន្ទប់ធ្វើការរបស់ខ្លួនរហូតដល់ម៉ោងប្រាំបួន និងសាមសិបនាទី ហើយបានជិះម៉ូតូចេញទៅបាត់រហូតតែម្ដង។

-<u>តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានដូចតទៅ :</u>

+ ដោយមានភាពស៊ីសង្វាក់រវាងសកម្មភាពប្រព្រឹត្ត និងភស្តុតាងគ្រាប់គ្រាន់ ហើយការឆ្លើយដោះសាររបស់ជនជាប់ចោទគ្មានមូលដ្ឋានអាចយកមកពិចារណាបាន។ តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ និងសំណូមពរដល់ចៅក្រមជំនុំជម្រះសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់ និងសកម្មភាពដែលបានប្រព្រឹត្ត។

+មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោះ [redacted] ច័ន្ទនួន ភេទស្រី អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ ជាប់ចោទពីបទ: សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិអណ្ដូងទឹក ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង កាលពីថ្ងៃ ទី១០, ១៣ ខែមីនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ២៩,៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

+មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោ [redacted] លក្ខិណា ភេទស្រី អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ ជាប់ចោទពីបទ: សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិអណ្ដូងទឹក ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង កាលពីថ្ងៃ ទី១០, ១៣ ខែមីនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ២៩,៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

+មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោះ [redacted] អ៊ីស៊ី ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរឥស្លាម ជាប់ចោទពីបទ៖ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិអណ្ដូងទឹក ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង កាលពីថ្ងៃទី១០, ១៣ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

+សូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ១៣៧ អ.យ/១៧ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៧ ទុកជាបានការទាំងស្រុង និងសូមឲ្យចៅក្រមជំនុំជម្រះពិនិត្យសម្រេចតាមច្បាប់។

Scanned by CamScanner

-មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើសេចក្ដីសន្និដ្ឋានដូចតទៅ :

មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើសេចក្ដីសន្និដ្ឋាន ដោយសុំឲ្យតុលាការពិចារណាផ្ដន្ទាទោសដល់ឈ្មោះ [redacted] អ៊ុំសើ ឲ្យបានធ្ងន់ធ្ងរ ព្រោះទង្វើរបស់ជនជាប់ចោទនេះបានធ្វើឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ខាតបង់ប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយបានធ្វើឲ្យអតិថិជនមានការបាត់បង់ទំនុកចិត្តមកលើគ្រឹះស្ថាន ។ ជាមួយគ្នានេះដែលលោកមេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងបានស្នើសុំសំណងជំងឺចិត្តចំនួន១០០០០(មួយម៉ឺន)ដុល្លា សហរដ្ឋអាមេរិច និងសំណងថ្លៃសេវាមេធាវីចំនួន១០០០០(មួយម៉ឺន)ដុល្លាសហរដ្ឋអាមេរិចនិងសូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះបន្ថែមបទចោទមួយករណីទៀត គឺបទ រំលោភទុកចិត្តពិសេសដោយពិសេសដោយអភិបាល ។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានដូចតទៅ :

សេចក្ដីសន្និដ្ឋានរបស់មេធាវីរបស់ជនជាប់ឈ្មោះ [redacted]លក្ខិណា និងឈ្មោះ [redacted] ច័ន្ទនួន ដែលលោកមេធាវីបានលើកឡើងនឹងស្នើសុំតុលាការឲ្យរួចផុតពីបទចោទ ។

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] អ៊ុំសើ បានសន្និដ្ឋានសុំឲ្យកូនក្ដីរបស់ខ្លួនរួចផុតពីបទចោទ ដោយលើកឡើងថាគ្មានភស្តុតាងច្បាស់លាស់ណាមួយបញ្ជាក់ថា ឈ្មោះ អែល អ៊ុំសើ បានប្រព្រឹត្ត ។

-សំដីចុងក្រោយរបស់ជនជាប់ចោទដែលមានវត្តមានចំពោះមុខសវនាការឈ្មោះ [redacted] ច័ន្ទនួន និងឈ្មោះ [redacted]លក្ខិណា បានស្នើសុំដល់ក្រុមប្រឹក្សាជំនុំជម្រះមេត្តាជួយរកយុត្តិធម៌ឲ្យដល់ពួកគេផងព្រោះពួកគេមិនបានរួមគំនិតលួចលុយរបស់គ្រឹះស្ថានប្រាសាក់ទេ គ្រាន់តែខ្លួនមានការធ្វេសប្រហែសទុកដាក់សោមិនបានត្រឹមត្រូវ ទើបធ្វើឲ្យឈ្មោះ [redacted] អ៊ុំសើលួចលុយបាន ។

1) ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ
2) ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ
3) ក្រោយពីបានពិនិត្យភស្តុតាង
4) ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកោះកុង

## យល់ឃើញថា

១-តាមចម្លើយរបស់ជនសង្ស័យឈ្មោះ [redacted]លក្ខិណា បានឆ្លើយសារភាពថា: ខ្លួនបានចូលបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់សាខាអណ្ដូងទឹកផ្នែកបេឡាធិការតាំងពី ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ មកម្ល៉េះ ដោយខ្លួនមិនបានកាន់សោទូរនោះទេ។ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ឈ្មោះ [redacted]អ៊ុំសើ នាយកសាខាអណ្ដូងទឹកបានប្រគល់សោមកឲ្យខ្លួនកាន់រួមមាន: សោបន្ទប់ទីមួយ សោបន្ទប់ទីពីរ សោទូរដែកខាងក្នុងមួយ និងសោទូរដែកបន្ទប់បម្រុងមួយ សរុបទាំងអស់មានចំនួនបួនសោ ហើយមិនដែលមានបញ្ហាអ្វីនោះទេ។ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំពីរ និងសាមសិបនាទីព្រឹក ខ្លួនបានទៅចាក់សោទូបន្ទប់ធម្មតា ហើយបានទៅចាក់សោទូដែកដោយមានគ្នាចំនួនបីនាក់ រួមមានឈ្មោះ [redacted]អ៊ុំសើ ឈ្មោះ មុកច័ន្ទនួន និងខ្លួន ដើម្បីយកប្រាក់បើក និងដកប្រាក់ឲ្យអតិថិជន។ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ វេលា



Scanned by CamScanner

ម៉ោងប្រាំពីរ និងដប់នាទីព្រឹក ខ្លួនបានមកធ្វើការធម្មតា ហើយឈ្មោះ [redacted] ច័ន្ទនួន ដែលជាប្រធានបេឡា បានហៅខ្លួនឲ្យចាក់សោជួចរាល់ដង និងមានឈ្មោះ [redacted] ផល្លី ប្រធានស្តីទីសាខា បានចាក់សោបន្ទប់ទីមួយ ទីពីរ និងចាក់សោបន្ទប់ទីពីរ ហើយបន្ទប់ទីពី ព្រមទាំងបានចាក់សោរទូរដែក ដោយឈ្មោះ [redacted] ផល្លី បានបង្វិលលេខកូដសម្ងាត់គឺលេខចាស់ ប៉ុន្តែឈ្មោះ [redacted] ផល្លី បានបង្វិលលេខកូដ ទូរដែកមិនចេញជាច្រើនលើករួចមកឈ្មោះ [redacted] ច័ន្ទនួន ដែលជាប្រធានបេឡា បានទាក់ទងថ្នាក់លើដែលជាប្រធានគ្រប់គ្រងតំបន់ និងអ្នកជំនាញទូដែក បានមកបើកទូរដែកតែបើកមិនចេញ ហើយក៏ទម្លុះទូដែកនោះតែម្តង។ចំណែកខ្លួនបានចេញមកខាងក្រៅដើម្បីទទួលអតិថិជន។ នៅពេលដែលទម្លុះទូដែក និងបានរាប់ប្រាក់រួចរាល់ហើយ ប្រធានបេឡា និងប្រធានស្តីទី បានចេញមកខាងក្រៅ ហើយខ្លួនបានសួរថា "យ៉ាងម៉េចហើយ" តែប្រធានបេឡា និងប្រធានស្តីទីបានក្រវីក្បាល ហើយខ្លួនបានទៅបម្រើការងារធម្មតា និងបានបិទបញ្ជី ។ បន្ទាប់មកប្រធានតំបន់ បានហៅបុគ្គលិកមកប្រជុំមួយភ្លាត តែមិនបានប្រជុំទេដោយសារម៉ោងប្រាំពីរយប់ហើយ។ លុះព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧ វេលា ម៉ោងប្រាំពីរ និងសែសិបនាទីព្រឹក ប្រធានតំបន់បានហៅបុគ្គលិកប្រជុំម្នាក់ម្តងៗដោយបានប្រាប់ថា "សាខាយើងមានបាត់ប្រាក់" ហើយប្រធានសាខាបានឲ្យពួកខ្លួនមកធ្វើការធម្មតាវិញ។ នៅត្រង់ចំណុចនេះបានបង្ហាញថា ការទុកដាក់សោសម្រាប់ចូល គឺឈ្មោះ [redacted] លក្ខិណា បានទុកសោនៅក្នុងការិយាល័យ នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដោយមិនបានយកតាមខ្លួននោះទេ ដែលត្រង់ចំណុចនេះបានបង្ហាញថាមានការធ្វេសប្រហែស ពាក់ព័ន្ធនឹងការថែរក្សាសោសុវត្ថិភាព ដែលបានហុចឱកាសឲ្យឈ្មោះ [redacted] អ៊ុំសើ ដឹងកន្លែងទុកដាក់សោរហូតរៀបចំគម្រោងលួចលុយក្នុងទូដែកតែម្តង ។

២-តាមចម្លើយរបស់ជនសង្ស័យឈ្មោះ [redacted] ច័ន្ទនួន បានឆ្លើយសារភាពថា: ខ្លួន បានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់បានអស់រយៈពេលពីរឆ្នាំ និងប្រាំមួយខែមកហើយ។ នៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៦ ខ្លួនបានកាន់សោតាំងពីនៅហានៈជាបុគ្គលិកមកម្ល៉េះ ដែលសោរទាំងនោះរួមមាន: សោបន្ទប់ប្រតិបត្តិការ សោបន្ទប់ត្រៀមបម្រុង សោទូបម្រុង (ទូដែកនៅខាងក្នុងសម្រាប់ដាក់ប្រាក់) និងសោទូដែកសម្រាប់ដាក់ប្រាក់ គឺទូដែកខ្នាតតូច ហើយអ្នកដែលកាន់សោរនេះមានគ្នាបីនាក់រួមមាន:ឈ្មោះ [redacted] អ៊ុំសើ កាន់សោបន្ទប់បម្រុងបន្ទប់ប្រតិបត្តិការនិងលេខកូដទូបម្រុង។ ខ្លួន ជាប្រធានបេឡា កាន់សោបន្ទប់ប្រតិបត្តិការ បន្ទប់ត្រៀមបម្រុង សោទូបម្រុង និងលេខកូដទូប្រតិបត្តិការ។ ចំណែកឈ្មោះ [redacted] លក្ខិណា ហានៈជាបេឡា កាន់សោរបន្ទប់ប្រតិបត្តិការ សោបន្ទប់ត្រៀមបម្រុង សោទូត្រៀមបម្រុង និងសោទូប្រតិបត្តិការ។ នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំមួយ និងសាមសិបនាទីព្រឹកជារៀងរាល់ថ្ងៃខ្លួនទៅបម្រើការងារនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ហើយតែងតែរង់ចាំអ្នកកាន់សោពីរនាក់ទៀតទើបអាចចាក់សោរបាន។នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំមួយ និងសាមសិបនាទីខ្លួនបានមកធ្វើការមុនគេ ចំណែកនាយកសាខាឈ្មោះ [redacted] អ៊ុំសើ អវត្តមានដោយត្រូវទៅរៀននៅភ្នំពេញ ដោយប្រាប់មន្ត្រីឥណទានថា បានផ្ទេរទៅឲ្យឈ្មោះ [redacted] ផល្លី ប្រធានស្តីទីសាខា ប៉ុន្តែនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧ ឈ្មោះ [redacted] អ៊ុំសើ មិនបានទៅរៀននៅភ្នំពេញទេ ហើយនាយកភូមិភាគនៅជាមួយនាយកសាខាខេត្តកោះកុង បានទូរស័ព្ទខ្លួនសួររកនាយកសាខាឈ្មោះ [redacted] អ៊ុំសើ ទៅណា? ហើយខ្លួនបានប្រាប់វិញថា "ឈ្មោះ [redacted] អ៊ុំសើ បានឡើងទៅប្រជុំនៅភ្នំពេញ ប៉ុន្តែនាយកសាខាភូមិភាគ និងនាយកសាខាខេត្តកោះកុង បានប្រាប់វិញថា មិនឃើញទេ។ បន្ទាប់មកខ្លួនក៏បានទំនាក់ទំនងជាមួយសន្តិសុខ ឈ្មោះ [redacted] ប៊ុនធឿន ហើយសន្តិសុខនោះបាន

Scanned by CamScanner

ប្រាប់វិញថា "នៅទេ គាត់ចេញបាត់តាំងពីម៉ោងប្រហែលប្រាំបួនកន្លះ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧"។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំមួយល្ងាច ខ្លួនបានចេញពីខេត្តកោះកុងទៅអណ្តូងទឹកវិញប្រហែលម៉ោងប្រាំពីរ និងសូន្យនាទីយប់ ខ្លួនបានសួរសន្តិសុខ ហើយសន្តិសុខបានបង្ហាញប្រអប់បាយដែលសន្តិសុខបានទិញបាយឲ្យ ហើយខ្លួនក៏បានទូរស័ព្ទមកនាយកសាខាខេត្តកោះកុង ហើយនាយកសាខាខេត្តកោះកុង បានប្រាប់ថាមិនឃើញទេ។ ចំពោះការឆ្លើយបញ្ជាក់របស់ឈ្មោះ [redacted] ចំនួននេះ ក៏មានលក្ខណៈដូចគ្នានឹងឈ្មោះ [redacted] លក្ខិណាដែរ ព្រោះពួកគេបានទុកសោនៅក្នុងការិយាល័យដូចគ្នា ដែលសកម្មភាពធ្វេសប្រហែសបែបនេះ ដែលបានហុចឱកាសឲ្យឈ្មោះ [redacted] អ៊ុំសើ ដឹងកន្លែងទុកដាក់សោរហូតរៀបចំគម្រោងលួចលុយក្នុងទូដែកតែម្តង ។

៣-តាមចម្លើយរបស់ឈ្មោះ [redacted] ណារិទ្ធ បានឆ្លើយបំភ្លឺថា:ឈ្មោះ [redacted] អ៊ុំសើ បានចូលបម្រើការងារជានាយកសាខាអណ្តូងទឹកកាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥ បានធ្វើសកម្មភាពលួចយកប្រាក់ក្នុងទូដែករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់នៅសាខាអណ្តូងទឹកអស់ប្រាក់ចំនួន ៥៥ លានរៀល និង៨១,៩៧០ ដុល្លារអាមេរិក។ ឈ្មោះ [redacted] អ៊ុំសើ មិនបានចូលមកធ្វើការនៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ ហើយតំណាងស្ថាប័នមីក្រូហិរញ្ញវត្ថុប្រាសាក់ បានធ្វើការទំនាក់ទំនងតាមទូរស័ព្ទតែទាក់ទងពុំបាន។ និងបានសួរនាំបុគ្គលិកសន្តិសុខដែលប្រចាំការនៅអណ្តូងទឹក បាននិយាយថា: កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រហែលប្រាំបួន ព្រឹកឈ្មោះ [redacted] អ៊ុំសើ បានចូលទៅបន្ទប់ធ្វើការងាររបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានប្រហែល មួយនាទីភ្លើង បានដាច់ និងប្រព័ន្ធកាមេរ៉ាសុវត្ថិភាពត្រូវបានកាត់ផ្តាច់ទាំងស្រុង។ ដោយឈ្មោះ [redacted] ណារិទ្ធ បាននិយាយថា:នៅវេលាម៉ោងប្រមាណប្រាំបួន និងសាមសិបនាទីព្រឹក ឈ្មោះ [redacted] អ៊ុំសើ បានចាកចេញពីសាខារបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ដោយស្ពាយកាបូប ពណ៌ខ្មៅដែលមានសម្ភារៈពេញ ។ បន្ទាប់មកថ្នាក់គ្រប់គ្រងបានបញ្ជូនបុគ្គលិកមកសាខា ដោយបង្កើតគណៈកម្មការត្រួតពិនិត្យទូដែក ក្រោយពីបានពិនិត្យ និងផ្ទៀងផ្ទាត់សាច់ប្រាក់រួច គណៈកម្មការត្រួតពិនិត្យបានបញ្ជាក់ថា: ឈ្មោះ [redacted] អ៊ុំសើ ពិតជាបានលួចយកប្រាក់ពីទូរដែកអស់ចំនួន៥៥លានរៀល និងប្រាក់ដុល្លារអាមេរិកចំនួន៨១៩៧០ ដុល្លារអាមេរិកប្រាកដមែន។ គ្រង់ចំណុចនេះបានបង្ហាញថា ឈ្មោះ [redacted] អ៊ុំសើបានរៀបចំគម្រោងទុកជាមុន ដើម្បីធ្វើ សកម្មភាពលួចលុយក្នុងទូដែករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់រហូតបានសម្រេច ។

៤-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ណារិទ្ធ បានឆ្លើយបំភ្លឺថា: កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧វេលាម៉ោងប្រាំបី និងសូន្យនាទីព្រឹក ខ្លួនជាសន្តិសុខរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់ប្រាសាក់សាខាអណ្តូងទឹក ។ នៅពេលដែលខ្លួនកំពុងយាមនៅជាន់ខាងក្រោមខ្លួនឃើញឈ្មោះ [redacted] សើ ជានាយកសាខាបានដើរចូលក្នុងស្នាក់ការ ហើយបានឡើងទៅជាន់ទីពីរ ដែលជាបន្ទប់ធ្វើការរបស់ឈ្មោះ [redacted] អ៊ុំសើ។ ឈ្មោះ [redacted] អ៊ុំសើ បានចុះមកជាន់ខាងក្រោមដែលជាកន្លែងខ្លួនយាម និងបានបើកទូរទស្សន៍មើលបានប្រហែលប្រាំនាទីភ្លើងក៏ដាច់ ហើយឈ្មោះ [redacted] អ៊ុំសើ បានឡើងទៅលើវិញ និងខ្លួនបានឃើញឈ្មោះ [redacted] អ៊ុំសើ ដើរចេញពីបន្ទប់ទឹកដោយមានសភាពសើមជោគនិងបានទៅអង្គុយលេងនៅកន្លែងចំណតម៉ូតូខាងមុខសាខា។ បន្ទាប់មកឈ្មោះ [redacted] អ៊ុំសើ បានប្រើឈ្មោះ [redacted] ប៊ុនធឿន ដែលជាសន្តិសុខ ទៅទិញបាយឲ្យនៅពេលដែលហូបបាយរួចឈ្មោះ [redacted] អ៊ុំសើ បានជិះម៉ូតូចេញទៅដោយមានកាបូបស្ពាយមួយ ប៉ុន្តែមិនបានយកចូលក្នុងស្នាក់ការទេ ហើយខ្លួនបានសួរឈ្មោះ [redacted] អ៊ុំសើ ថា "នាយកទៅណា" ហើយឈ្មោះ [redacted] អ៊ុំសើ បានឆ្លើយថា ទៅប្រជុំនៅភ្នំពេញ"។

Scanned by CamScanner

សាក្សីឈ្មោះ [redacted] ណារិទ្ធ បានបន្ថែមទៀតថា កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំពីរព្រឹក ខ្លួនបានទៅយាមនៅសាខា។ ខ្លួនបានឃើញឈ្មោះ [redacted] អ៊ុំសើ ដែលជានាយកសាខាអណ្ដូងទឹក ទៅធ្វើការនៅសាខា ខ្លួនបានឃើញឈ្មោះ [redacted] អ៊ុំសើ រៀបចំចេញដំណើរ ហើយខ្លួនបានសួរថា នាយកសាលាទៅណា ហើយឈ្មោះ [redacted] អ៊ុំសើ បានឆ្លើយថា ទៅហូបការគេនៅត្រពាំងរុង។ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំបួន និងសូន្យនាទីព្រឹក ខ្លួនបានឃើញឈ្មោះ [redacted] អ៊ុំសើ មកការិយាល័យប្រាសាក់សាខា អណ្ដូងទឹក ហើយបានអង្គុយមើលទូរទស្សន៍។ បន្ទាប់មកបានឡើងទៅសម្រាកនៅបន្ទប់ធ្វើការនៅជាន់ទីពីរ។ រហូតដល់ម៉ោងដប់បី និងសូន្យនាទី ឈ្មោះ [redacted] អ៊ុំសើ បានជិះម៉ូតូចេញទៅក្រៅបាត់តែម្ដង។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោងប្រាំបីព្រឹក ខ្លួនបានឃើញឈ្មោះ [redacted] អ៊ុំសើ ចូលមកសាខាអណ្ដូងទឹក និងបានឡើងទៅបន្ទប់ធ្វើការរបស់ខ្លួនរហូតដល់ម៉ោងប្រាំបួន និងសាមសិបនាទី ហើយបានជិះម៉ូតូចេញទៅបាត់រហូតតែម្ដង។ តាមចម្លើយសាក្សីនេះ មានភាព ស៊ីសង្វាក់ទៅសកម្មភាពប្រព្រឹត្តល្មើសរបស់ឈ្មោះ [redacted] អ៊ុំសើ ។

៥-តាមកំណត់ហេតុរបស់គណៈកម្មាការផ្ទៀងផ្ទាត់ការបាត់ប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ បានបង្ហាញថា លុយដែលបាត់បង់មានចំនួន ក្នុងនោះប្រាក់រៀលមានចំនួន៥៥.០០០.០០០(ហាសិបប្រាំលាន)រៀល និងប្រាក់ដុល្លាមានចំនួន ៨១៩៧០(ប្រាំបីម៉ឺនមួយពាន់ប្រាំបួនរយចិតសិប)ដុល្លាសហរដ្ឋអាមេរិច ។ គប្បីតុលាការពិនិត្យ និងពិចារណា ។

៦ -ជនជាប់ចោទឈ្មោះ [redacted] លក្ខិណា និងឈ្មោះ [redacted] ច័ន្ទនួន ត្រូវបានចៅក្រមស៊ើបសួរសម្រេចអនុញ្ញាតឲ្យនៅក្រៅឃុំ ដែលការសម្រេចនេះមិនបានបង្កឲ្យមានផលប៉ះពាល់ដល់នីតិវិធីស៊ើបសួរឡើយ ហើយម្យ៉ាងទៀតពួកគេមានកិច្ចសហការណ៍ល្អគ្រប់ដំណើរការនីតិវិធីរបស់តុលាការ ។ គប្បីតុលាការពិចារណាសម្រេចអំពីការព្យួរទោសដល់ជនជាប់ចោទដែលជាស្ត្រីទាំងពីររូបនេះ ។

៧- ផ្អែកតាមមាត្រា១០៦ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ គប្បីតុលាការធ្វើការពិចារណាចំពោះជនជាប់ចោទដែលជាស្ត្រីទាំងពីររូប ឈ្មោះ [redacted] លក្ខិណា និងឈ្មោះ [redacted] ច័ន្ទនួន ។

៨ - ផ្អែកតាមសេចក្ដីសន្និដ្ឋានរបស់មេធាវីរបស់ជនជាប់ឈ្មោះ [redacted] លក្ខិណា និងឈ្មោះ [redacted] ច័ន្ទនួន ដែលលោកមេធាវីបានលើកឡើងនឹងស្នើសុំតុលាការឲ្យរួចផុតពីបទចោទ តុលាការយល់ឃើញថា បទល្មើសដែលជនជាប់ចោទទាំងពីរបានប្រព្រឹត្តគឺកើតចេញពីការធ្វេសប្រហែសតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការទុកដាក់ថៃរក្សាសោ ដែលការខ្ជីខ្ជារនេះបាននាំឲ្យមានបទល្មើសកើតឡើង ។

៩- ផ្អែកតាមចម្លើយសាក្សី និងភស្តុតាងដែលបានលើកឡើងក្នុងសវនាការ មានពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] អ៊ុំសើ ក្នុងអំពើលួចមានស្ថានទម្ងន់ ។

១០-តំណាងអយ្យការបានសន្និដ្ឋានតម្កល់ការចោទប្រកាន់ ។

១១-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] អ៊ុំសើ បានសន្និដ្ឋានសុំឲ្យកូនក្ដីរបស់ខ្លួនរួចផុតពីបទចោទ ដោយលើកឡើងថាគ្មានភស្តុតាងច្បាស់លាស់ណាមួយបញ្ជាក់ថា ឈ្មោះ [redacted] អ៊ុំសើ បានប្រព្រឹត្ត ។ ការលើកឡើងរបស់លោកមេធាវីការសិទ្ធិនេះ តុលាការមិនធ្វើការពិចារណានោះទេ ព្រោះក្រោយការប្រព្រឹត្តបទល្មើសឈ្មោះ [redacted] អ៊ុំសើ បានរត់គេចខ្លួនរហូត មិនបានចូលខ្លួនតាមនីតិវិធីរបស់តុលាការឡើយ ។

Scanned by CamScanner

១២-មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសេចក្តីសន្និដ្ឋាន ដោយស្នើសុំឲ្យតុលាការពិចារណាផ្តន្ទាទោសដល់ឈ្មោះ[redacted]អ៊ុំសើ ឲ្យបានធ្ងន់ធ្ងរ ព្រោះទង្វើរបស់ជនជាប់ចោទនេះបានធ្វើឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ខាតបង់ប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់ ហើយ បានធ្វើឲ្យអតិថិជនមានការបាត់បង់ទំនុកចិត្តមកលើគ្រឹះស្ថាន ។ ជាមួយគ្នានេះដែល លោកមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងបានស្នើសុំសំណងជំងឺចិត្តចំនួន១០០០០(មួយម៉ឺន)ដុល្លា សហរដ្ឋអាមេរិច និងសំណងថ្លៃសេវាមេធាវីចំនួន១០០០០(មួយម៉ឺន)ដុល្លា សហរដ្ឋអាមេរិច ។ តុលាការយល់ឃើញថា ទង្វើរបស់ជនជាប់ឈ្មោះ[redacted]អ៊ុំសើ ដែលបានប្រព្រឹត្តបទល្មើស ហើយរត់គេចខ្លួននេះ ពិតជាបង្កឲ្យមានការខូចខាតយ៉ាងច្រើនដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ អាស្រ័យហេតុនេះ គប្បីតុលាការពិចារណាផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]អ៊ុំសើ ដោយផ្អែកតាមអង្គហេតុ និងព្យសនកម្មដែលបានកើតមាន ។ ចំពោះសំណងជំងឺចិត្ត និងការខូចខាតផ្សេងៗដែលដើមបណ្តឹងបានលើកឡើង តុលាការយល់ឃើញថាពិតជាមានការខូចខាត ដែលត្រូវសងដល់ដើមបណ្តឹងរដ្ឋប្បវេណីពិតប្រាកដមែន ហេតុដូចនេះគប្បីតុលាការពិចារណាសម្រេចដោយផ្អែកលើព្យសនកម្ម និងការខូចខាតជាក់ស្តែងដែលបានកើតឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណី ពីសំណាក់ជនជាប់ចោទឈ្មោះ[redacted]អ៊ុំសើ ។

១៣- ផ្អែកតាមមាត្រា៣៥៣ មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១៤- ផ្អែកតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

១៥-យោងតាមមាត្រា៩៦ នៃក្រមព្រហ្មទណ្ឌ តុលាការប្រកាសទោសដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅកិរិយាមារយាទរបស់ជនល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

**១-ផ្តន្ទាទោស៖**

ក/.ឈ្មោះ[redacted]អ៊ុំស៊ី ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរឥស្លាម ដាក់ពន្ធនាគារកំណត់ ០៧(ប្រាំពីរ)ឆ្នាំ ។

ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង កាលពីថ្ងៃទី១០, ១៣ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមាន ចែងឲ្យ ផ្តន្ទាទោសតាមមាត្រា៣៥៣,៣៥៧នៃក្រមព្រហ្មទណ្ឌ ។

ខ/.ឈ្មោះ [redacted] ច័ន្ទទូន ភេទស្រី អាយុ ២៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន០៣ (បី)ឆ្នាំ តែទោសនេះត្រូវព្យួរ ។

ជាប់ចោទពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិអណ្តូងទឹកឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង កាលពីថ្ងៃ ទី១០, ១៣ ខែមីនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៩,៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

គ/.ឈ្មោះ[redacted]បត្តិណា ភេទស្រី អាយុ ២៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៣(ឆ្នាំ) តែទោសនេះត្រូវព្យួរ ។

Scanned by CamScanner

ជាប់ចោទពីបទៈ សមគំនិតក្នុងអំពើលួចដោយស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិអណ្ដូងទឹក ឃុំអណ្ដូង ទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង កាលពីថ្ងៃ ទី១០, ១៣ ខែមីនា ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៩,៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២- បង្គាប់ឲ្យចាប់ខ្លួន៖

ក/. ឈ្មោះ [redacted] អ៊ីសើ ភេទប្រុស ជនជាតិខ្មែរឥស្លាម ។

៣ - បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] អ៊ីសើ សងប្រាក់ទៅឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាកសាក់ រួមមាន ៖

ក/. សងប្រាក់ដែលបានបាត់បង់រួមមាន៖

-ប្រាក់រៀលចំនួន ៥៥.០០០.០០០ (ហាសិបប្រាំលាន)រៀល ។

-ប្រាក់ដុល្លាចំនួន៨១៩៧០(ប្រាំបីម៉ឺនមួយពាន់ប្រាំបួនរយចិតសិប)ដុល្លាសហរដ្ឋអាមេរិច ។

ខ/. សងប្រាក់ថ្លៃជំងឺចិត្ត និងការខូចខាតផ្សេងៗចំនួន៨០.០០០.០០០ (សែសិបលាន) រៀល ។

៤- សាលក្រមនេះបានបើកសវនាការជាសាធារណៈនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចំនួនទួន និងឈ្មោះ [redacted] លក្ខិណា និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] អ៊ីសើ ។

បើកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
កោះកុង ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨
ក្រឡាបញ្ជី
[redacted]

បានឃើញ
កោះកុង ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted]



Scanned by CamScanner